**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ...៥២... សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបញ្ចូលឯកសារលក្ខណវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធរបស់ប្រកាស លេខ ៤២ ដនស.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៨១/២៦ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីការការពារបេតិកភ័ណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet. Com. kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការអនុវត្តច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីស្តីពីការបង្កើត ការចាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញប្រកាសលេខ ៤២ ដនស បក ចុះថ្ងៃទី១០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- បានទទួលមតិឯកភាពក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

ប្រការ ១: បញ្ចូលឯកសារលក្ខណៈវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាឧបសម្ព័ន្ធរបស់ប្រកាសលេខ ៤២ ដនស.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។

ប្រការ ២: ឯកសារស្តីពីលក្ខណៈវិនិច្ឆ័យក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ មានខ្លឹមសារដូចតទៅ ÷

## I - និយមន័យ

ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ និងអនុក្រឹត្យ លេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា ៤ និងមាត្រា ៥ បានចែងពីនិយមន័យនៃដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ដូចតទៅ :

១. ដីសាធារណៈរបស់រដ្ឋ :

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម :

ក. ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិ ដូចជា ÷

១. ព្រៃឈើ ។

២. ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៣. បឹងធម្មជាតិ ។

៤. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៥. ត្រើយសមុទ្រ ។

ខ. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ដូចជា ÷

១. តំរវ៉ាន ។

២. កំពង់ផែ ។

៣. ស្ថានីយរថភ្លើង ។

៤. ផ្លូវដែក ។

៥. ព្រលានយន្តហោះ ។

គ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា ÷

១. ផ្លូវថ្នល់ ។

២. ផ្លូវលំ ។

៣. ផ្លូវរទេះ ។

៤. ផ្លូវដើរ ។

៥. សួនច្បារ ឧទ្យានសាធារណៈ ។

៦. ដីចំណី ។

ឃ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា ÷

១. សាលារៀន ឬ អគារសិក្សាសាធារណៈ ។

២. អគាររដ្ឋបាល ។

៣. មន្ទីរពេទ្យសាធារណៈ ។

ង. ដែនបម្រុងធម្មជាតិការពារដោយច្បាប់ ។

ច. បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ឆ. អចលនទ្រព្យជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ជ. ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ ។

២. ដីឯកជនរបស់រដ្ឋ :

ដីឯកជនរបស់រដ្ឋរួមមាន ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាល ឆ្នាំ ២០០១។ ដីឯកជនរបស់រដ្ឋ មានរួមបញ្ចូលដូចជា ទ្រព្យនិទាឃាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬ ទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់ ។

## II - លក្ខណវិនិច្ឆ័យ ឬស្តង់ដារ សម្រាប់ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

| ប្រភេទដីរដ្ឋ | បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ | លក្ខណវិនិច្ឆ័យ | យន្តការ |
|---|---|---|---|
| - ព្រៃឈើ | - រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ ចែងថាព្រៃឈើជាសម្បត្តិរបស់រដ្ឋ ។<br><br>- ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ព្រៃឈើ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>- អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ មាត្រា ៤ ក៏បានចែងថា ព្រៃឈើ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>- ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ ដែលមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ មោះជាប្រភេទព្រៃនោះ កើតឡើងដោយធម្មជាតិក្តី ឬ ដោយដាំក្តី ។ | . ដីក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិទោះបីជាដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធាន សត្វព្រៃ និងធនធានធម្មជាតិ ដទៃទៀត ដែលស្ថិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺផល អនុផលព្រៃឈើ ឬសេវាកម្ម ដែលផ្តល់ដោយព្រៃឈើក្រៅពីព្រៃឯកជន ។<br>. ឬ ដើមឈើតូចៗ ដែលដុះដោយធម្មជាតិ ជាផ្នែកមួយនៃតំបន់ព្រៃឈើ ត្រូវបានកាប់បំផ្លាញ ព្រៃឈើដោយមនុស្ស ឬដោយគ្រោះធម្មជាតិ ដែលនឹងក្លាយទៅជាព្រៃឈើ ។<br>. ឬ អតីតដីព្រៃឈើ ដែលកន្លងមក | - ផ្ទៃដីព្រៃទាំងអស់នឹងត្រូវកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ ដោយយន្តការដែលមានកំណត់ក្នុងអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវចុះពិនិត្យ និងកំណត់ឱ្យបានច្បាស់លាស់ នូវព្រំប្រទល់ដីព្រៃឈើ ដោយប្រើប្រាស់រូបថតពីលើអាកាស អំពីគម្របព្រៃឈើ ដែលថតនៅឆ្នាំ ២០០២ គូបផ្សំនឹងព័ត៌មានទាំងឡាយ ដែលទទួលបាននៅលើដីជាក់ស្តែង ។<br><br>- ការសិក្សាកំណត់ ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |

| | | | |
|---|---|---|---|
| | - អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។<br><br>- សេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ ។<br><br>- សេចក្តីប្រកាសលេខ ០៦ ប្រ.ក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីរដ្ឋ ។<br><br>- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុំព័ទ្ធកាន់កាប់ដីព្រៃឈើ ។<br>- បទបញ្ជាលេខ ០១ ប.ប. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ការកាប់រានព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋ យកធ្វើជាកម្មសិទ្ធិ ។<br><br>- លិខិតលេខ ៥៨៤ សជណ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការសម្រេចកំណត់យកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ជាផែនទីគោលសម្រាប់ជាមូលដ្ឋាននៃការកំណត់ព្រំប្រទល់ដែន ព្រៃឈើ ។ | ទទួលរងការកាប់បំផ្លាញព្រៃឈើ ដោយកត្តាមនុស្ស កត្តាធម្មជាតិ ដែលនឹងអាចស្តារគម្របព្រៃឈើឡើងវិញបាន ។<br>• ព្រៃឈើរដ្ឋគ្របដណ្តប់លើដី ដែលមិនមែន ជាកម្មសិទ្ធិឯកជន និងត្រូវបានចាត់ថ្នាក់ជាព្រៃផ្តល់ផល ព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។<br><br>• ចំពោះដីស្ថានីយ៍ស្រាវជ្រាវ និងមណ្ឌលអភិវឌ្ឍផ្សេងៗ ព្រមទាំងដីត្រៀមបម្រុងផ្សេងៗទៀត ដែលគ្រប់គ្រងដោយអង្គភាពនានា ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ។ ចំពោះលក្ខណវិនិច្ឆ័យត្រូវផ្អែកលើឯកសារ និងការកាន់កាប់ជាក់ស្តែង នៃយន្តការគ្រប់គ្រងបច្ចុប្បន្នរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យ លេខ ៥៣ អនក្រ.បក ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ មានសមត្ថកិច្ច និងភារកិច្ចក្នុងការបង្កើតប្រភេទដីព្រៃ និងកំណត់ព្រំប្រទល់នៃប្រភេទដីព្រៃនោះនៅក្នុងរង្វង់ព្រំប្រទល់ដីដែលត្រូវបានកំណត់ ដោយយន្តការគ្រប់គ្រងដីរដ្ឋថា ពិតជាដីព្រៃ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីព្រៃ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ (ដែលអាចចុះសេចក្តី នោះបន្ថែមនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីផងដែរ) ។ |
| - ដែននេសាទព្រៃលិចទឹក និង ព្រៃកោងកាង | - ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ ដែលមានវិសាលភាពគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាង ដែលទាក់ទងនឹងវដ្តជីវិតនៃធនធានជលផល ។ ច្បាប់នេះចែងថា ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រដែលមានតួនាទីសំខាន់បំរើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល ។ ដែនដីលិចទឹកអចិន្ត្រៃយ៍ មានជាអាទិ៍ សមុទ្រ | - នាទីព្រៃលិចទឹក និងនាទីព្រៃកោងកាង ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ដីបឹងនានា ក្រៅពីបឹងធម្មជាតិ ដែលត្រូវបានកំណត់ជាផ្នែកមួយនៃឡូត៍នេសាទ ឬកន្លែងនេសាទដទៃទៀត ដែលត្រូវបានកំណត់ថាជាទ្រព្យសម្បត្តិរបស់រដ្ឋ អនុលោមតាមក្រឹត្យ- ច្បាប់ លេខ ៣៣ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ ១៩៨៧ និងប្រកាសរបស់ក្រសួង | - ដែននេសាទទាំងអស់នឹងត្រូវកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ដោយយន្តការដែលមានកំណត់ក្នុងអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។<br><br>- យន្តការដែលបង្កើតឡើងដោយ ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង |

| | | | |
|---|---|---|---|
| | ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និង ប្រឡាយ ។ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង ភណ្តៅ វាលភក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកឡើង និងនាទីព្រៃលិចទឹក ។ ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទី ព្រៃកោងកាង ។<br><br>ដែននេសាទ ជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ព្រំប្រទល់នៃដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។ ការបង្កើត ការរំសាយតំបន់គ្រប់គ្រងជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ នីតិវិធី នៃការបង្កើត ឬ រំសាយតំបន់ជលផលត្រូវកំណត់ដោយអនុក្រឹត្យ ។<br><br>ដែននេសាទអាចគ្រប់ដណ្តប់លើដីសាធារណៈ ឬ ដីកម្មសិទ្ធិឯកជន នារដូវទឹកឡើង ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ ។ រាល់ការប្រើប្រាស់ដែននេសាទដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបានលុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។<br><br>- ប្រកាសលេខ ០០៦៧ ប្រក.កសក ស្តីពីការកំណត់ នាទីព្រៃដែលជាដែននេសាទទឹកសាប និង សមុទ្រ ។ | កសិកម្ម ស្តីពីការកំណត់ព្រំប្រទល់នាទីឡូត៍នេសាទ និង កន្លែងនេសាទបម្រុង ( មុនមានការកាន់កាប់ជាភោគៈស្រប ច្បាប់ ឬជាកម្មសិទ្ធិស្របច្បាប់ ) ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ដីក្នុងតំបន់ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ ស្របតាមច្បាប់ស្តីពីជលផលឆ្នាំ២០០៦ ដោយកាត់ចេញដីដែលត្រូវបានកាប់កាន់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិស្របច្បាប់ ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។ | នេសាទ មានសមត្ថកិច្ច និងភារកិច្ចធ្វើចំណាត់ថ្នាក់ដែននេសាទទាំងឡាយក្នុងរង្វង់ព្រំប្រទល់ដែននេសាទ ដែលត្រូវបានកំណត់ថាពិតជាដែននេសាទតាមមូលដ្ឋានគតិយុត្តជាធរមាន ។ |
| - ភ្នំ | - រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ ចែងថា ភ្នំ ជាសម្បត្តិរបស់រដ្ឋ ។ ប៉ុន្តែ មិនបានធ្វើចំណាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋឡើយ ។ | - ភ្នំ ឬចំណែកណាមួយនៃភ្នំដែលមានជាប់ប្រយោជន៍សាធារណៈ ឬ មានការប្រើប្រាស់ជាសាធារណៈ ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ភ្នំ ឬចំណែកណាមួយនៃភ្នំ ដែលមិន | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីភ្នំ ឬចំណែកណាមួយនៃភ្នំដែលជាប់ប្រយោជន៍សាធារណៈ ឬមាន |

| | | | |
|---|---|---|---|
| | | មានជាប់ប្រយោជន៍សាធារណៈ ឬ មិនមានការប្រើប្រាស់ជាសាធារណៈ ហើយ មិនមានការកាន់កាប់ជាឯកជន ស្របច្បាប់ ត្រូវចាត់ថ្នាក់ជាដីឯកជន របស់រដ្ឋ ។ | ការប្រើប្រាស់ជាសាធារណៈ ឬ ដែលមិនទាន់មានការកាន់កាប់ ជាឯកជនស្របច្បាប់ ។<br><br>- ការសិក្សាកំណត់ខាងលើនេះក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - ត្រើយសមុទ្រ (seashore)<br>- ឆ្នេរសមុទ្រ (seaside) | - រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ ចែងថា សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ ជាសម្បត្តិរបស់រដ្ឋ ។ ប៉ុន្តែមិនមានបញ្ចូលពាក្យត្រើយសមុទ្រទេ ។<br><br>- ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ត្រើយសមុទ្រ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ ប៉ុន្តែមិនមានបញ្ចូលពាក្យថា ឆ្នេរសមុទ្រទេ ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា១២ ចែងថា ឆ្នេរ និងច្រាំងមច្ឆេ សមុទ្រ ព្រែក ស្ទឹង ជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ហើយត្រូវហាមឃាត់មិនឱ្យសាងសង់ ។ ប៉ុន្តែមិនមានការកំណត់ទំហំឆ្នេរទេ ។ | - ត្រើយសមុទ្រ ក្នុងន័យនៃឯកសារលក្ខណវិនិច្ឆ័យនេះ គឺជាផ្ទៃដីដែលឋិតនៅចន្លោះខ្សែបន្ទាត់ទឹកជោរ និងទឹកនាច ។ ត្រើយសមុទ្រត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ឆ្នេរសមុទ្រ ដែលនៅជាប់ត្រើយសមុទ្រឡើងមកលើរហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានា (setback line) ហើយមានថ្ម ឬខ្សាច់ ដែលគួរកំណត់ទុកជាតំបន់សម្រាប់ ប្រើប្រាស់ជាសាធារណៈ ហើយចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br>ចំពោះផ្នែកណាមួយនៃឆ្នេរសមុទ្រ ដែលគ្មានការកាន់កាប់ជាកម្មសិទ្ធិឯកជនស្របច្បាប់ ឬ មានការចូលកាន់កាប់មិនស្របច្បាប់ក្រោយច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន គួរកំណត់តំបន់ ឆ្នេរសមុទ្រ ដោយវាស់តាមខ្សែស្របនឹងផ្ទៃទឹកសមុទ្រ<br>- ចំពោះឆ្នេរជម្រាល គួរកំណត់ ៣០ ទៅ ៥០ ម៉ែត្រ ចាប់រាប់ពីខ្សែបន្ទាត់ទឹកជោរ (ដែលអាចមានស្មៅដុះ) ។<br>- ចំពោះច្រាំងចោទ គួរកំណត់យក ពី ២០ ទៅ ៣០ ម៉ែត្រ ចាប់រាប់ពីចំណុចកំពូលនៃផ្ទៃចោទ ។ | - ព្រំប្រទល់ត្រើយសមុទ្រ និង ឆ្នេរសមុទ្រ គួរកំណត់ឱ្យបានច្បាស់លាស់ ដោយយន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក. ស្តីពីការគ្រប់គ្រងដីរដ្ឋត្រូវចុះពិនិត្យ និង កំណត់ឱ្យបានច្បាស់លាស់នូវព្រំប្រទល់ត្រើយសមុទ្រ និង ឆ្នេរសមុទ្រដែលត្រូវកំណត់ទុកជាដីសាធារណៈរបស់រដ្ឋ ។<br>- ការសិក្សាកំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - កោះធំ<br>កោះតូច<br>និង ដីដុះ | - រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ ចែងថា កោះជាសម្បត្តិរបស់រដ្ឋ ។ ប៉ុន្តែ មិនបានធ្វើចំណាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋឡើយ ។ | - កោះណាមួយ ឬផ្នែកខ្លះនៃកោះ ដែលបង្ហាញឱ្យឃើញច្បាស់ថា មានប្រយោជន៍សាធារណៈ ឬមានការប្រើប្រាស់ជាសាធារណៈ ត្រូវចាត់ថ្នាក់ជាដីសាធារណៈ | យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់ |



roch

| | | | |
|---|---|---|---|
| | - ច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ៣២ ចែងថា កោះធំ កោះតូចទាំងឡាយ ដីដែលដុះក្នុងផ្ទៃទន្លេ ឬស្ទឹង ព្រែក ដែលជាទីអាចដើរបាន អាចបណ្តែតនាវា ក្បូនបាន ត្រូវបានមករដ្ឋតាមបទបញ្ជាដែលមានជាធរមាន ។<br>-មាត្រា ៣៣ ចែងថា កោះធំ កោះតូចទាំងឡាយ និង ដីដុះក្នុងស្ទឹង ព្រែក មិនជាទីដើរ បណ្តែតនូវក្បូនទេ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅនឹងមាត់ស្ទឹង មាត់ព្រែក ខាងកោះដុះនោះ បើកោះនោះ មិនដុះជ្រុលទៅម្ខាងទេនោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីនៅត្រើយទាំងពីរខាង យកតាមបន្ទាត់ដែលគេសន្មត់ថាពុះពាក់កណ្តាលស្ទឹងជាប្រមាណ ។<br>- អនុក្រឹត្យលេខ ៥៣ អនក្រ.បក ឆ្នាំ ១៩៩៥ មាត្រា២ ចែងថា ក្នុងន័យនេះ ដីដែលដុះចាស់ឬថ្មីជាកោះនៅសមុទ្រ ទន្លេ ព្រែក ស្ទឹង បឹងបួរ ខូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាសជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមិនអនុញ្ញាតឱ្យឯកជន ឬ សមូហភាពប្រកាសជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ។<br>- ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១០២ ចែងថា កោះធំ កោះតូចនិងដីដុះទាំងឡាយ ដែលនឹងកកើតថ្មីក្នុងផ្ទៃទន្លេ ឬ ស្ទឹង ព្រែក ដែលនាវា ឬក្បូនចេញ ចូលបាន បណ្តែតបាន ជារបស់រដ្ឋ ។ មាត្រា ១០៣ ចែងថា កោះធំ កោះតូចនិងដីដុះទាំងឡាយដែលនឹងកកើតថ្មីក្នុងស្ទឹង ព្រែក ដែលនាវា ឬក្បូនចេញចូលមិនបាន បណ្តែតមិនបាន ត្រូវបានមកកម្មសិទ្ធិករនៃដីជាប់ច្រាំង ដែលមានកោះ ឬដីដុះនោះ ។ ប្រសិនបើការដុះនោះមិនបានដុះជ្រុលទៅច្រាំងម្ខាងទឡោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីជាប់ច្រាំងទាំងសងខាង គិតពីបន្ទាត់ពុះពាក់កណ្តាលស្ទឹង ។ | របស់រដ្ឋ ក្រៅពីនេះត្រូវចាត់ទុកជា ដីឯកជនរបស់រដ្ឋ ។<br>- កោះធំតូច ឬចំណែកនៃកោះ ដែលមានការចូលកាន់កាប់ជា ភោគៈស្របច្បាប់ មុនច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមានអាចផ្តល់ជាកម្មសិទ្ធិឯកជន ។<br>- ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរឡើងលើ ។<br>- ចំណែកឯកោះក្នុង ទន្លេ ស្ទឹង ព្រែក ត្រូវកំណត់ត្រឹមកម្រិតទឹកនៅរដូវវស្សានៃឆ្នាំដែលធ្វើការកំណត់នោះ លើកលែងតែមានទឹកជំនន់ខុសធម្មតា ។<br>- ដីចន្លោះខ្សែបន្ទាត់ទឹកនៅរដូវប្រាំង និងខ្សែបន្ទាត់ទឹកនៅរដូវវស្សា នៃកោះ អាចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់បណ្តោះអាសន្ន និងមិនទៀង តាមរយៈកិច្ចសន្យាច្បាស់លាស់ ។ | ជាកោះណា ឬចំណែកនៃកោះណាមួយជារបស់រដ្ឋ ដែលមិនទាន់បានកាន់កាប់ដោយឯកជនស្របច្បាប់ មុនច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន ។<br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - ទន្លេ | -រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ បានចែងថា ទន្លេជាសម្បត្តិរបស់រដ្ឋ ។ | - ទន្លេគឺជាផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ហើយដែលត្រូវបានកំណត់ថាជាទន្លេ ។ នៅព្រះរាជាណាចក្រ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា |

| | | | |
|---|---|---|---|
| | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថាផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ | កម្ពុជាមានទន្លេទាំងអស់ ៧ គឺ ទន្លេមេគង្គ ទន្លេសាប ទន្លេបាសាក់ ទន្លេសេកុង ទន្លេសេសាន ទន្លេស្រែពក និងទន្លេតូច ។<br><br>- ដីទន្លេគឺជាដីដែលឋិតនៅចន្លោះច្រាំងទាំងសងខាង ដែលមានទឹកជាប្រចាំនៅរដូវប្រាំង ។ ដីទន្លេ ជាដីសាធារណៈរបស់រដ្ឋ ។ តាមច្បាប់ភូមិបាល ឆ្នាំ ២០០១ ច្រាំងទន្លេត្រូវបានចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ដូចទន្លេដែរ ដូច្នេះមិនចាំបាច់ធ្វើការកំណត់ព្រំប្រទល់ដីទន្លេទេ ប៉ុន្តែជាការចាំបាច់ត្រូវកំណត់ ឱ្យច្បាស់នូវខ្សែបន្ទាត់ ផ្នែកខាងលើនៃច្រាំងទន្លេ ។ | និងកំណត់ច្បាស់លាស់អំពីព្រំប្រទល់ច្រាំងទន្លេ ។<br><br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - ច្រាំងទន្លេ | - ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចាត់ទុកច្រាំងទន្លេ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា ១២ ចែងថា ឆ្នេរ និងច្រាំងទន្លេ សមុទ្រ ព្រែក ស្ទឹង ជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ហើយត្រូវហាមឃាត់មិនឱ្យសាងសង់ ប៉ុន្តែមិនមានការកំណត់ទំហំឆ្នេរទេ ។<br><br>- គ្មានច្បាប់ ឬលិខិតបទដ្ឋានណាមួយបានកំណត់ថាត្រូវមានដីចំណីទន្លេ ចំណីព្រែក ឬចំណីស្ទឹងទេ ។ | -ច្រាំងទន្លេជាដីសាធារណៈរបស់រដ្ឋ ។<br><br>-ច្រាំងទន្លេ ជាផ្នែកនៃដីដែលនៅចន្លោះខ្សែបន្ទាត់នៃកម្រិតទឹកទាបបំផុតនៅរដូវប្រាំង និងខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតនៅរដូវវស្សានៃឆ្នាំកំណត់ព្រំប្រទល់នោះ លើកលែងករណីឆ្នាំដែលមានទឹកជំនន់ខុសធម្មតា ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីព្រំប្រទល់ច្រាំងទន្លេ ។<br><br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន (ក្រៅពីទន្លេ) | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ផ្លូវទឹកដែលនាវា ឬក្បូន ចេញចូលបាន បណ្តែតបាន ត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ មាត្រា ២២៧ ចែងថា ក្បាលដីឬឯកតាសុរិយោដី គឺជាផ្ទៃដីមួយជាក់លាក់ស្ថិតនៅក្នុងឃុំ ឬសង្កាត់តែមួយ មិនពុះបំបែកដោយព្រំជាប់មិនដាច់ជារបស់ជនម្នាក់ ឬច្រើននាក់ក្នុងករណីអវិភាគកម្ម ហើយប្រើប្រាស់ក្នុងរូបភាពតែមួយ ។ ចាត់ទុកជាព្រំជាប់មិនដាច់ដែលនាំឱ្យបំបែកក្បាលដីជាច្រើនក្បាល គឺរបងផ្លូវសាធារណៈ | - ដីផ្លូវទឹកដែលនាវា ឬក្បូន ចេញចូលបាន បណ្តែតបាន (ក្រៅពីទន្លេ) ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ ។<br><br>-ទទឹងផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា ។<br><br>- ដីផ្លូវទឹកដែលនាវា ឬក្បូន ចេញចូល | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីផ្លូវទឹកទាំងឡាយ និងព្រំប្រទល់ដី ផ្លូវទឹកដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ការសិក្សាកំណត់ខាងលើនេះ ត្រូវផ្អែកលើ ផែនការប្រើប្រាស់ដី |



rach

| | | | |
|---|---|---|---|
| | ប្រឡាយ និងផ្លូវទឹកដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ ។<br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា១២ និង ច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ២១៧ ចែងថា ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដែលបណ្តែតក្បូនបាន ឬមិនបាន ប្រឡាយបង្ហូរទឹកចេញចូល ត្រូវចាត់ចូលជាសម្បត្តិសាធារណៈទាំងអស់ ។ | មិនបាន បណ្តែតមិនបាន ត្រូវចាត់ទុកជាដីឯកជនរបស់រដ្ឋ ។<br><br>- ប្រសិនបើទទឹងផ្លូវទឹកនោះមានទំហំតិចជាង ២ ម៉ែត្រ អាចចុះបញ្ជីផ្លូវទឹកនោះជាចំណែកនៃក្បាលដីឯកជនបាន ។ ប៉ុន្តែអាចមានបន្ទុកសេវភាពចំពោះផ្លូវទឹកនោះប្រសិនបើក្បាលដីនោះជាកម្មសិទ្ធិឯកជន ។ | ប្រសិនបើមាន ។ |
| - បឹងធម្មជាតិ | -រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៥៨ ចែងថា បឹង ជាសម្បត្តិរបស់រដ្ឋ ។<br><br>-ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា បឹងធម្មជាតិ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ ប៉ុន្តែគ្មានច្បាប់ ឬលិខិតបទដ្ឋានណាមួយដែលកំណត់អំពីចំណីបឹងទេ ។ | - តួបឹងធម្មជាតិជាដីសាធារណៈរបស់រដ្ឋ ហើយត្រូវកំណត់យកត្រឹមខ្សែបន្ទាត់កម្រិតទឹកនៅរដូវប្រាំងនៃឆ្នាំកំណត់ព្រំប្រទល់បឹង លើកលែងឆ្នាំដែលមានភាពរាំងស្ងួតខុសធម្មតា ។<br><br>- ដីដែលស្ថិតនៅចន្លោះខ្សែបន្ទាត់កម្រិតទឹកទាបបំផុតនៅរដូវប្រាំង និងខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតនៅរដូវវស្សា ចាត់ទុកជាដីឯកជនរបស់រដ្ឋ លើកលែងតែចំណែកណានៃផ្ទៃដីនោះ ដែលបង្ហាញថាមានប្រយោជន៍សាធារណៈ ឬការប្រើប្រាស់ជាសាធារណៈ ដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីបឹងធម្មជាតិ និងព្រំប្រទល់បឹង ។<br><br>- ការសិក្សា កំណត់ខាងលើនេះត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន ។ |
| - គីរបាន<br>- កំពង់ផែ | - ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា គីរបាន និង កំពង់ផែ ដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ | -ដីគីរបាន ឬកំពង់ផែ ដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ហើយទំហំដីត្រូវកំណត់តាមប្លង់គីរបាន ឬប្លង់កំពង់ផែ ដែលបានអនុម័តជាផ្លូវការ ។<br><br>- ដីគីរបាន ឬ ដីកំពង់ផែ ដែលមិនបានរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ អាចស្ថិតនៅលើដីឯកជនរបស់រដ្ឋ លើដីសម្បទាន ឬនៅលើដីកម្មសិទ្ធិរបស់បុគ្គលឯកជន ដែលត្រូវកំណត់តាមករណីជាក់ស្តែងទីមួយៗ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងដោយមានការចូលរួមផងដែរពីតំណាងអាជ្ញាធរកំពង់ផែ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីព្រំប្រទល់គីរបាន និងកំពង់ផែ ដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ការសិក្សា កំណត់ខាងលើនេះត្រូវផ្អែកលើ ផែនការប្រើប្រាស់ដីប្រសិនបើមាន ។ |

| | | | |
|---|---|---|---|
| - ផ្លូវដែក ស្ថានីយរថភ្លើង និង ដីចំណីផ្លូវដែក | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ផ្លូវដែក ស្ថានីយរថភ្លើង ដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ និងដីចំណីជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br>មាត្រា ១៤៨ ចែងថា ការកំណត់ព្រំដីនិងកម្មសិទ្ធិដែលស្ថិតនៅតាមបណ្តោយផ្លូវសាធារណៈត្រូវកំណត់ ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ ...។ នៅពេលដែលអាជ្ញាធរ ធ្វើការសម្រេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលស្ថិតនៅលើបន្ទាត់តម្រង់ផ្លូវ ត្រូវបន្ថយទៅក្រោយ ។ បើជារបងធម្មតា ឬ ជាសំណង់ស្រាលអាជ្ញាធរតម្រូវឱ្យធ្វើការរើកិលចេញ ។ ប្រសិនបើជាអចលនវត្ថុ ដែលមិនអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរ កែសម្រួលរុះរើបាន អចលនវត្ថុនោះ ត្រូវស្ថិតក្នុងសភាពដដែលសិន រហូតដល់ដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេចអំពីការពង្រីកដែលបានគ្រោងទុក ។ ការដកហូតកម្មសិទ្ធិមួយចំណែក ឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយអនុវត្តត្រឹមត្រូវ តាមនីតិវិធីនៃច្បាប់ ។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ ព្រមទាំងរបង និងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ម្ចាស់កម្មសិទ្ធិ មានសិទ្ធិទាមទារឱ្យសងការខូចខាតរបស់ខ្លួន ។<br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា ១២ និងច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ៥ ចែងថា ដីបម្រុង និងដីចំណីសម្រាប់ផ្លូវដែក ឬផ្លូវរថភ្លើង ត្រូវចាត់ទុកជាសម្បត្តិសាធារណៈ ។<br>- សេចក្តីប្រកាសលេខ ០៦ ប្រ.ក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការទប់ស្កាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីរដ្ឋ ។ | - ដីផ្លូវដែក ដីស្ថានីយរថភ្លើង និង ដីចំណីផ្លូវដែក ជាដីសាធារណៈរបស់រដ្ឋ ។<br>- ដីចំណីផ្លូវដែកត្រូវបានកំណត់ដូចតទៅ :<br>. ទំហំ ២០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះទីក្រុង ទីរួមខេត្ត និងទីប្រជុំជន<br>. ទំហំ ៣០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកដែលស្ថិតនៅក្រៅក្រុង ។<br>. ទំហំ ១០០ ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ចំពោះផ្លូវដែកដែលនៅតំបន់ព្រៃភ្នំ ដែលមានថ្មរមាលធ្លាក់ ឬតំបន់ព្រៃខ្ពស់ ។<br>- ទំហំដីនៃស្ថានីយ៍រថភ្លើងត្រូវកំណត់តាមប្លង់នៃស្ថានីយ៍ដែលបានអនុម័តជាផ្លូវការ ។<br>- ដីបម្រុងខុសពីដីចំណីផ្លូវ ។ ចំពោះដីបម្រុងទុកធ្វើផ្លូវរថភ្លើង ឬស្ថានីយរថភ្លើង ត្រូវអនុវត្តតាមមាត្រា ១៤៨ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ។<br>- គួរកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់តំបន់ទីប្រជុំជន ទីរួមខេត្ត និងទីក្រុង ឱ្យបានច្បាស់លាស់ ។ | - យន្តការដែលមានចែងក្នុង អនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីដីផ្លូវដែក ឬ ដីចំណីផ្លូវដែក និង ស្ថានីយរថភ្លើងទាំងឡាយ ដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ។<br>- ក្រុមប្រឹក្សាគោលនយោបាយដីធ្លី គួរស្វែងរកការឯកភាពគ្នាក្នុងការកំណត់វិសាលភាព ទីប្រជុំជន ទីរួមខេត្ត និងទីក្រុង ឱ្យបានច្បាស់លាស់សម្រាប់គោលបំណងនៃការចុះបញ្ជីដី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។<br>- យន្តការដីរដ្ឋ ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីកំណត់ព្រំប្រទល់ជាក់ស្តែងនៅលើដី នៃទីប្រជុំជន ទីរួមខេត្ត ទីក្រុង និងតំបន់ព្រៃភ្នំដែលមានថ្មរមាលធ្លាក់ ឬតំបន់ព្រៃខ្ពស់ ។<br>- ការសិក្សា កំណត់ខាងលើនេះ ត្រូវផ្អែកលើ ផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - ព្រៃលាន | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែង | - ដីព្រៃលានយន្តហោះដែលរៀបចំពិសេស | - យន្តការដែលមានចែងក្នុង |



nach

| | | | |
|---|---|---|---|
| យន្តហោះ | ថា ព្រលានយន្តហោះដែលរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា ១២ ចែងថា ដីបម្រុងទុកសម្រាប់អាកាសយានដ្ឋាន ជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ។ | សម្រាប់ប្រយោជន៍ទូទៅចាត់ទុក ជាដីសាធារណៈរបស់រដ្ឋ ។ ប៉ុន្តែបើមិនបានរៀបចំពិសេសទុកសម្រាប់ប្រយោជន៍ទូទៅទេនោះ អាចជាដីឯកជនរបស់រដ្ឋ ។ | អនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋដោយមានការចូលរួមផងដែរពីតំណាងអាកាសចរស៊ីវិល ត្រូវសិក្សា និងកំណត់ច្បាស់លាស់អំពីដីព្រលានយន្តហោះ និងដីបម្រុងទុកសម្រាប់ធ្វើអាកាសយានដ្ឋាន ដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈ របស់រដ្ឋ ។<br>- ការសិក្សា កំណត់ខាងលើនេះ ត្រូវផ្អែកលើ ផែនការប្រើប្រាស់ដីប្រសិនបើមាន ។ |
| -ផ្លូវថ្នល់ (ផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវឃុំ) និង ដីចំណីផ្លូវ | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ផ្លូវថ្នល់ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ និងដីចំណីផ្លូវ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ មាត្រា ១៤៨ ចែងថា ការកំណត់ព្រំដី និងកម្មសិទ្ធិដែលស្ថិតនៅតាមបណ្តោយផ្លូវសាធារណៈត្រូវកំណត់ ដោយអាជ្ញាធរមានសមត្ថកិច្ច យោងតាមសេចក្តីត្រូវការជាក់ស្តែងនៃផលប្រយោជន៍រួម ពិសេសតាមសេចក្តីត្រូវការនៃការធ្វើចរាចរ ... ។ នៅពេលដែលអាជ្ញាធរធ្វើការសម្រេចពង្រីកទំហំផ្លូវ សំណង់ទាំងឡាយដែលស្ថិតនៅលើបន្ទាត់តម្រង់ផ្លូវ ត្រូវបន្ថយទៅក្រោយ ។ បើជារបងធម្មតា ឬ ជាសំណង់ស្រាល អាជ្ញាធរតម្រូវឱ្យធ្វើការរំកិលចេញ ។ ប្រសិនបើជាអចលនវត្ថុ ដែលមិនអាចជា កម្មវត្ថុនៃការផ្លាស់ប្តូរកែសម្រួលរុះរើបាន អចលនវត្ថុនោះត្រូវស្ថិតក្នុងសភាពដដែលសិន រហូតដល់ពេលអាជ្ញាធរមានសមត្ថកិច្ចសម្រេចអំពីការពង្រីកដែលបានគ្រោងទុក ។ ការដកហូតកម្មសិទ្ធិមួយចំណែក ឬទាំងស្រុងអាចប្រព្រឹត្តទៅបានដោយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃច្បាប់ ។ ចំពោះដីដែលបានកាន់កាប់ស្របច្បាប់ព្រមទាំងរបង និងសំណង់ទាំងឡាយដែលបានធ្វើឡើងត្រឹមត្រូវតាមបញ្ញត្តិនៃច្បាប់ ម្ចាស់កម្មសិទ្ធិមានសិទ្ធិទាមទារ | - ផ្លូវថ្នល់ មានបីប្រភេទគឺ ផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវឃុំ ។ ផ្លូវថ្នល់ និងដីចំណីផ្លូវថ្នល់ ជាដីសាធារណៈរបស់រដ្ឋ ។<br>- ផ្លូវក្នុងទីក្រុង ទីរួមខេត្ត ទីរួមស្រុក មិនចាំបាច់មានដីចំណីទេ ប៉ុន្តែត្រូវមានចិញ្ចើមផ្លូវ ។ ដីផ្លូវ និងចិញ្ចើមផ្លូវទាំងនេះ ក៏ជាដីសាធារណៈរបស់រដ្ឋដែរ ។<br><br>*- សម្រាប់គោលបំណងនៃការចុះបញ្ជីដីផ្លូវថ្នល់ ត្រូវបានកំណត់និយមន័យដូចតទៅ :*<br>- ផ្លូវជាតិ គឺសំដៅដល់ផ្លូវថ្នល់ទាំងឡាយដែលអាជ្ញាធរមានសមត្ថកិច្ច បានប្រកាស ឬកំណត់ថាជាផ្លូវជាតិ ។ ជាទូទៅ ផ្លូវជាតិ គឺជា :<br>១- ផ្លូវដែលតភ្ជាប់ពីរាជធានីទៅទីរួមខេត្ត និងព្រំដែនអន្តរជាតិ<br>២- ផ្លូវដែលតភ្ជាប់ពីទីរួមខេត្តមួយ ទៅទីរួមខេត្តមួយទៀត និងទៅព្រំដែនអន្តរជាតិ ។<br><br>- ផ្លូវខេត្ត គឺជា :<br>១. ផ្លូវដែលតភ្ជាប់ពីទីរួមស្រុកមួយទៅទីរួមស្រុកមួយទៀត<br>២. ផ្លូវដែលតភ្ជាប់ពីទីរួមស្រុកមួយទៅទីរួមខេត្ត ឬរាជធានី | -ចំពោះតំបន់ទីប្រជុំជន ទីរួមខេត្តក្រុង ទីក្រុង និងចំណីផ្លូវយន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងលើកអនុសាសន៍អំពីព្រំប្រទល់ដីផ្លូវថ្នល់ ដីបម្រុង ឬដីចំណីផ្លូវថ្នល់ទាំងឡាយដែលត្រូវចាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ។ ទន្ទឹមនេះយន្តការខាងលើអាចលើកអនុសាសន៍ផងដែរក្នុងករណីដែលពិនិត្យឃើញថាអាចមានផលប៉ះពាល់សង្គមតិចតួច ឬក្នុងកម្រិតដែលរដ្ឋអាចមានលទ្ធភាពសងសំណងចំពោះការដកហូតសិទ្ធិលើទ្រព្យ និងតាមលទ្ធភាពរៀបចំការផ្លាស់ប្តូរទីតាំង ឬការតាំងទីលំនៅថ្មី សមស្របសម្រាប់អ្នកដែលត្រូវបង្ខំឱ្យចាកចេញពីដីផ្លូវឬចំណីផ្លូវនោះ ។<br><br>-ក្នុងតំបន់ដែលមិនមែនជាទីប្រជុំជន ទីរួមខេត្ត ទីក្រុង គឺអាចអនុវត្តតាមប្រកាសលេខ ០៦ ប្រក. ឆ្នាំ ១៩៩៩ តែត្រូវមានសំណងចំពោះការដកហូតសិទ្ធិ |

| | | | |
|---|---|---|---|
| | ឱ្យសងការខូចខាតរបស់ខ្លួន ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា១២ ចែងថា ដីបម្រុងទុកសម្រាប់ផ្លូវជាទីធ្លាដែលមានលក្ខណៈជាសាធារណៈ ។<br><br>- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០៦ ប្រក. ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ។ | ៣. ផ្លូវដែលតភ្ជាប់ពីផ្លូវជាតិមួយទៅផ្លូវជាតិមួយទៀត<br>៤. ផ្លូវដែលតភ្ជាប់ពីផ្លូវជាតិមួយទៅទីរួមខេត្ត ។<br><br>- ផ្លូវឃុំ គឺជា :<br>១. ផ្លូវដែលតភ្ជាប់ពីស្រុកមួយទៅស្រុកមួយទៀត<br>២. ផ្លូវដែលតភ្ជាប់ពីស្រុកមួយទៅឃុំមួយ<br>៣. ផ្លូវដែលតភ្ជាប់ពីឃុំមួយទៅឃុំមួយទៀត ។<br><br>ដីចំណីផ្លូវថ្នល់ត្រូវបានកំណត់ដូចតទៅ :<br>- ផ្លូវជាតិលេខ ១. ៤. ៥ កំណត់ទំហំ ៣០ ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ។<br>-ផ្លូវជាតិលេខ ១ខ្ទង់ ដូចជា លេខ ២. ៣. ៦. ៧ កំណត់ទំហំ ២៥ម ពីសងខាងអ័ក្សផ្លូវ ។<br>-ផ្លូវជាតិលេខ ២ខ្ទង់ មានជា អាទិ៍ លេខ ១១. ២២. ៦៤. ៧៨ កំណត់ទំហំ ២៥ ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ។<br>-ផ្លូវខេត្តកំណត់ទំហំ ២០ម៉ែត្រ ពីសងខាងអ័ក្ស ផ្លូវ<br>-ផ្លូវឃុំកំណត់ទំហំ១៥ ម៉ែត្រ ពីសងខាងអ័ក្សផ្លូវ ។<br>-ចំពោះតំបន់ទីប្រជុំជន ទីរួមខេត្ត ទីក្រុង ការកំណត់ដីចំណីផ្លូវខាងលើនេះ មិនយកមកអនុវត្តទេ ។<br>- ត្រូវកំណត់លក្ខណវិនិច្ឆ័យសម្រាប់កំណត់តំបន់ទីប្រជុំជន ទីរួមខេត្ត ទីក្រុង ឱ្យបានច្បាស់លាស់ ។<br>-ការផ្លាស់ប្តូរទំហំផ្លូវ ត្រូវអនុវត្តតាមមាត្រា ១៤៨ នៃច្បាប់ភូមិបាល ។ | នានាលើដីដល់ប្រជាពលរដ្ឋដែលបានកាន់កាប់ដី ដោយស្របច្បាប់ភូមិបាលឆ្នាំ ១៩៩២ មុនការចេញសេចក្តីប្រកាសខាងលើ ហើយក៏ត្រូវយកចិត្តទុកដាក់ដល់សំណងចំពោះការដកហូតសិទ្ធិលើទ្រព្យ និងលទ្ធភាពរៀបចំការផ្លាស់ប្តូរទីតាំង ឬការតាំងទីលំនៅថ្មីសមស្របសម្រាប់អ្នកដែលត្រូវបង្ខំឱ្យចាកចេញពីដីផ្លូវឬចំណីផ្លូវនោះ ។<br><br>- ក្រុមប្រឹក្សាគោលនយោបាយដីធ្លី គួរស្វែងរកការឯកភាពគ្នាក្នុងការកំណត់វិសាលភាពទីប្រជុំជន ទីរួមខេត្ត និងទីក្រុង ឱ្យបានច្បាស់លាស់សម្រាប់គោលបំណងនៃការចុះបញ្ជីដី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។<br><br>- យន្តការដីរដ្ឋ ត្រូវរៀបចំធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីកំណត់ព្រំប្រទល់ជាក់ស្តែងនៅលើដី នៃទីប្រជុំជន ទីរួមខេត្ត ទីក្រុង និងលើកសំណើដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីទំហំសមស្របជាក់លាក់ សម្រាប់កំណត់ ដីចំណីផ្លូវថ្នល់ក្នុងតំបន់ទីប្រជុំជន ទីរួមខេត្ត ទីក្រុងនីមួយៗ តាមស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការក្នុងមូលដ្ឋាន ។<br>- ការសិក្សា កំណត់ខាងលើនេះ ត្រូវផ្អែកលើផែនការប្រើប្រាស់ដីប្រសិនបើមាន ។ |
| - ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ | - ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ ដែលត្រូវបានដាក់ឱ្យប្រើជាសាធារណៈ ត្រូវចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ | - ដីផ្លូវលំ ផ្លូវរទេះ និង ផ្លូវដើរ ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ផ្លូវលំ គឺជាផ្លូវដែលតភ្ជាប់ពីភូមិមួយ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋដែលមានការចូលរួមផងដែរពីក្រុម |

| | | | |
|---|---|---|---|
| | -គ្មាននិយមន័យ និងគ្មានលិខិតបទដ្ឋានណាមួយ កំណត់អំពីទំហំ ផ្លូវលំ ផ្លូវរទេះ និងផ្លូវដើរទេ ។ | ទៅភូមិមួយឬច្រើនភូមិក្នុងឃុំតែមួយ ដែលអាចបើករថយន្តបាន ។<br><br>- ផ្លូវរទេះ គឺកំណត់យកផ្លូវដែលអ្នកស្រុកជាច្រើនក្នុងភូមិឬឃុំ បាននិងកំពុងប្រើប្រាស់សម្រាប់បររទេះ ធ្វើដំណើរទៅមកជាញឹកញាប់ ។<br>- ផ្លូវដើរ គឺជាផ្លូវដែលតភ្ជាប់ពីបុកផ្ទះមួយទៅបុកផ្ទះមួយ ក្នុងភូមិតែមួយ ឬផ្លូវភ្លឺព្រែក ឬទំនប់ប្រឡាយដែលយ៉ាងច្រើនបំផុតអាចជិះបានត្រឹមម៉ូតូ ឬកង់ ។<br>- ផ្លូវលំ ផ្លូវរទេះ និង ផ្លូវដើរ មិនចាំបាច់មានដីចំណីផ្លូវទេ ។ ប៉ុន្តែ គួរកំណត់ទំហំផ្លូវទាំងនោះ តាមការព្រមព្រៀងគ្នាទៅរបស់អ្នកភូមិភាគច្រើន ដូចខាងក្រោម :<br>. *ផ្លូវលំ : ៤-៦ ម៉ែត្រ*<br>. *ផ្លូវរទេះ : ៣-៤ ម៉ែត្រ*<br>. *ផ្លូវដើរ : ១-២ ម៉ែត្រ ។* | ប្រឹក្សាឃុំ-សង្កាត់ គួរពិនិត្យ និងកំណត់តាមករណីជាក់ស្តែងនិមួយៗ ដោយថ្លឹងថ្លែងការប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍភូមិ-ឃុំ ។<br><br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| - សួនច្បារ និង ឧទ្យានសាធារណៈ | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ រាប់បញ្ចូលទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា សួនច្បារ និងឧទ្យានសាធារណៈ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា ១២ ចែងថា សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិរក្សន៍ ជាទីធ្លាមានលក្ខណៈសាធារណៈ ។ | - សួនច្បារ និងឧទ្យានសាធារណៈ ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- សួនច្បារ និងឧទ្យានសាធារណៈមិនមានន័យដូចគ្នានឹងឧទ្យានជាតិ ដែលកំណត់ដោយព្រះរាជក្រឹត្យស្តីពីការកំណត់ និងការបង្កើតតំបន់ការពារធម្មជាតិនោះទេ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់សួនច្បារ និងឧទ្យានសាធារណៈទាំងឡាយដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ |
| សាលារៀនឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល និងមន្ទីរពេទ្យសាធារណៈ | - ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចាត់ទុកសាលារៀនឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល និងមន្ទីរពេទ្យ ដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ | - ដីសាលារៀនឬអគារសិក្សាសាធារណៈ ដីអគាររដ្ឋបាល និង ដីមន្ទីរពេទ្យឬមណ្ឌលសុខភាពសាធារណៈ ព្រមទាំងបរិវេណទីធ្លានៃគ្រឹះស្ថានទាំងនេះដែលឋិតនៅលើដីរដ្ឋ គឺជាដីសាធារណៈរបស់រដ្ឋ ។ | -យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និង កំណត់ដី ឬចំណែកដីសាលារៀន អគារសិក្សា អគាររដ្ឋបាល មន្ទីរ ពេទ្យ និងមណ្ឌលសុខភាពរដ្ឋទាំងឡាយដែលជាដីសាធារណៈរបស់រដ្ឋ ។ |



ឈ្មោះ

| | | | |
|---|---|---|---|
| | | | - ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| ដែនបំរុងធម្មជាតិការពារដោយច្បាប់ ( តំបន់ការពារធម្មជាតិ ) | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់ ( តំបន់ការពារធម្មជាតិ) រាប់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br>-ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ឆ្នាំ ១៩៩៣ ហើយដែលត្រូវបានចែងយោងក្នុងច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២ ។ ព្រះរាជ្យក្រឹត្យនេះចែងថា ប្រព័ន្ធការពារធម្មជាតិ រួមបញ្ចូលរាល់ប្រភេទដែនបម្រុងទុក សម្រាប់ឧទ្យានជាតិ ដែនជម្រកសត្វព្រៃតំបន់ ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ។ ព្រះរាជ្យក្រឹត្យនេះ បានកំណត់តំបន់ ការពារធម្មជាតិចំនួន ២៣កន្លែង នៅទូទាំង ប្រទេសកម្ពុជា ដែលក្នុងនោះ មានឧទ្យាជាតិ ៧កន្លែង ដែនជម្រកសត្វព្រៃ ១០កន្លែង តំបន់ការពារទេសភាព ៣កន្លែង និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ៣កន្លែង ។ ប៉ុន្តែព្រះរាជ្យក្រឹត្យមិនបានកំណត់ថាដី ក្នុងតំបន់ការពារធម្មជាតិទាំងនោះជា ដីសាធារណៈរបស់រដ្ឋទេ ។<br>- ផែនទី ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃព្រះរាជក្រឹត្យ បានគូសបញ្ជាក់អំពីទីតាំងតំបន់ការពារធម្មជាតិទាំង ២៣ កន្លែង ហើយមានការកំណត់ទំហំជាក់លាក់នៃតំបន់ការពារធម្មជាតិនិមួយៗ ប៉ុន្តែពុំមានការកំណត់ព្រំប្រទល់ច្បាស់លាស់គ្រប់គ្រាន់ទេ ។ ក្រសួងបរិស្ថានបានធ្វើផែនទីកំណត់ព្រំប្រទល់លើតំបន់ការពារធម្មជាតិបាន១៧កន្លែងរួចហើយ ។<br>- នៅលើដីជាក់ស្តែងក៏មិនទាន់បានបោះបង្គោលព្រំប្រទល់គ្រប់គ្រាន់នៅឡើយដែរទេ ។<br>-ច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ៥ ចែងថា មិនឱ្យមានសិទ្ធិជាឯកជនក្នុងដែនបម្រុងរុក្ខានៃសាទ អាងតំកល់ទឹកស្រោចស្រពបរិវេណមណ្ឌលរ៉ែ មណ្ឌលបេតិកភ័ណ្ឌវប្បធម៌ ប្រវត្តិ | - ជាទូទៅ ដីក្នុងដែនបម្រុងធម្មជាតិការពារដោយច្បាប់ ( ដីក្នុងតំបន់ការពារធម្មជាតិ) ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ការកំណត់ព្រំប្រទល់ជាក់លាក់នៃក្បាលដីក្នុងតំបន់ការពារធម្មជាតិទាំងនេះ ដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ត្រូវកាត់ចេញ ក្បាលដីឬចំណែកនៃដីទាំងឡាយណា ដែលប្រជាពលរដ្ឋបានកាន់កាប់ជាភោគៈស្របច្បាប់មុនពេលចេញព្រះរាជ្យក្រឹត្យ ហើយមានការបន្តកាន់កាប់ស្របច្បាប់រហូតមក ទោះជាបានទទួលការផ្ទេរសិទ្ធិពីអ្នកកាន់កាប់មុនក៏ដោយ ហើយត្រូវកំណត់ក្បាលដី ឬចំណែកដីនោះជាកម្មសិទ្ធិឯកជនស្របច្បាប់ ។<br>រដ្ឋអាចកំរិតសិទ្ធិប្រើប្រាស់លើដីឯកជននោះបាន តាមរយៈច្បាប់ បទបញ្ជា ឬ លិខិតបទដ្ឋានគតិយុត្តនានានៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។ ដីឯកជនស្របច្បាប់ដែលត្រូវកាត់ចេញ និងមិនចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ក៏នៅតែស្ថិតនៅក្រោមសមត្ថកិច្ចទូទៅរបស់ក្រសួងបរិស្ថានដដែល ។<br><br>- គួរកំណត់ក្បាលដី ឬចំណែកដីដែលមានការចូលកាន់កាប់ប្រើប្រាស់ក្រោយពេលចេញព្រះរាជក្រឹត្យនិងមុនច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមានផងដែរ ព្រោះអ្នកទាំងនោះអាចមានសិទ្ធិប្រើប្រាស់ដីនោះដោយត្រូវអនុវត្តស្របតាមច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានានៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។<br><br>- បន្តធ្វើផែនទីកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ និងបោះបង្គោលព្រំប្រទល់ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ និងត្រូវមានការចូលរួមរបស់មន្ត្រី ឬអតីតមន្ត្រីអាជ្ញាធរដែនដីក្នុងតំបន់និមួយៗ ត្រូវធ្វើការសិក្សា និងកំណត់ព្រំប្រទល់លើដីជាក់ស្តែងធ្វើផែនទីផ្លូវការនិងបោះបង្គោលព្រំប្រទល់លើដីជាក់ស្តែងឱ្យបានគ្រប់គ្រាន់ និងកំណត់អំពីការកាន់កាប់មុនព្រះរាជក្រឹត្យនិងក្រោយព្រះរាជក្រឹត្យ ។<br><br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |

| | | | |
|---|---|---|---|
| | សាស្ត្រជាតិ .... អតីតសំណង់រដ្ឋ ...។ ប៉ុន្តែច្បាប់នេះមិនបានហាមឃាត់ការប្រើប្រាស់ដោយឯកជនទេ ។<br>- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០៦ ប្រ.ក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ក៏បានបញ្ជាក់ការហាមឃាត់ មិនឱ្យមានសិទ្ធិជាឯកជនលើដីតំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ ...។<br>-បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ បង្ក្រាប លុបបំបាត់ការកាន់កាប់ ការឈ្លូសឆាយា និងការរុំព័ទ្ធដីព្រៃពេញ ត្រង់ចំណុចទី ១០ បានចែងថា រាល់ការចេញលិខិតឬប័ណ្ណ សំគាល់កម្មសិទ្ធិ និងការហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ការបោះទីតាំងមូលដ្ឋានទ័ព ការស្ថាបនាផ្លូវសាធារណៈ ការតាំងទីលំនៅថ្មី ... ដែលពាក់ព័ន្ធ តំបន់ការពារធម្មជាតិ ត្រូវធ្វើការពិគ្រោះយោបល់ និងមានការយល់ព្រមពីក្រសួងបរិស្ថាន ជាមុន ។<br>- បទបញ្ជាលេខ ០១ បប. ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិបានកំណត់ឱ្យគ្រប់ក្រសួង ស្ថាប័ន ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានទាំងពាក់ព័ន្ធដីព្រៃឈើគ្រប់ប្រភេទដែលមានជាធរមាន ដើម្បីដាក់ទោសចំពោះជនណាដែលបានរំលោភបំពានលើដីព្រៃឈើ គ្រប់ប្រភេទយកធ្វើជាកម្មសិទ្ធិ ។<br>- ច្បាប់ស្តីពីការអនុម័តយល់ព្រមអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសត្វស្លាបទឹក ឆ្នាំ ១៩៩៦ ចែងថា រាជរដ្ឋាភិបាលកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ និងលិខិតលេខ ៤០១០ អជ.កបទ.សអ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៩ ចែងថា ពិធីសារស្នើសុំដាក់តំបន់ដីសើម ៣ កន្លែងនៅក្នុងព្រះ | នៅលើដីជាក់ស្តែងឱ្យបានច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់ ។<br><br>- ដីតំបន់ដីសើម ៣ កន្លែង ដែលមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសម្រាប់សត្វស្លាបទឹក ត្រូវកំណត់ជាដីសាធារណៈរបស់រដ្ឋ ។ តំបន់ដីសើម ៣ កន្លែង រួមមានតំបន់ កោះកាពិ នៅខេត្តកោះកុង តំបន់បឹងទន្លេឆ្មារ នៅខេត្តកំពង់ធំ និងតំបន់រាមសារ នៅខេត្តស្ទឹងត្រែង ។ | |

| | | | |
|---|---|---|---|
| | រាជាណាចក្រកម្ពុជា បានទទួលចុះក្នុងបញ្ជីតំបន់ដីសើមអន្តរជាតិតាមអនុសញ្ញារ៉ាមសារ ។ | | |
| បេតិកភ័ណ្ឌ បុរាណវិទ្យា វប្បធម៌ និង ប្រវត្តិសាស្ត្រ | -ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៥ ចែងថា បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និង ប្រវត្តិសាស្ត្រ រាប់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ។<br><br>- ច្បាប់ភូមិបាលឆ្នាំ ១៩៩២ មាត្រា ៥ បានចែងហាមឃាត់មិនឱ្យមានកម្មសិទ្ធិឯកជនក្នុងមណ្ឌលបេតិកភ័ណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ ... ។<br><br>- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ កំណត់ថា រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ ជាទីធ្លាមានលក្ខណៈសាធារណៈ ។<br><br>- សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០៦ ប្រ.ក ឆ្នាំ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី បានចែងហាមឃាត់មិនឱ្យមានសិទ្ធិឯកជននៅក្នុងមណ្ឌលបេតិកភ័ណ្ឌវប្បធម៌ ។ | - បេតិកភ័ណ្ឌបុរាណវិទ្យា វប្បធម៌ និង ប្រវត្តិសាស្ត្រ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ។<br>- បេតិកភ័ណ្ឌអាចត្រូវបានគេរកឃើញនៅក្នុងដីឬលើដី ដែលជាកម្មសិទ្ធិឯកជនផងដែរ ។<br><br>- ប្រសិនបើ បេតិកភ័ណ្ឌនោះស្ថិតនៅក្នុងឬនៅលើដីរដ្ឋ ហើយការដកយកបេតិភ័ណ្ឌចេញពីដីនោះ មិននាំឱ្យធ្លាក់តម្លៃ ឬអស់តម្លៃនៃបេតិកភ័ណ្ឌនោះទេ ដីនោះត្រូវចាត់ទុកជាដីឯកជនរបស់រដ្ឋ ។ ប៉ុន្តែបើការដកយកបេតិកភ័ណ្ឌចេញពីដីនោះ នឹងនាំឱ្យបេតិកភ័ណ្ឌធ្លាក់តម្លៃឬអស់តម្លៃ ចាំបាច់ត្រូវតែរក្សាបេតិកភ័ណ្ឌទុកលើទីតាំងដដែល ហើយ ដីរដ្ឋនោះត្រូវចាត់ទុកជាដីសាធារណៈ របស់រដ្ឋ ។<br>- ប្រសិនបើរកឃើញបេតិកភ័ណ្ឌនៅក្នុងឬនៅលើដីជាកម្មសិទ្ធិរបស់បុគ្គលឯកជន ហើយការដកយកបេតិកភ័ណ្ឌចេញពីដីនោះ មិននាំឱ្យធ្លាក់តម្លៃ ឬអស់តម្លៃនៃបេតិកភ័ណ្ឌនោះទេ ត្រូវដកយកបេតិកភ័ណ្ឌ ចេញពីដីកម្មសិទ្ធិឯកជននោះ ។ ប៉ុន្តែ បើការ ដកយកបេតិកភណ្ឌចេញពីដីនោះ នឹងនាំឱ្យធ្លាក់ចុះតម្លៃ ឬអស់តម្លៃនៃបេតិកភ័ណ្ឌ ជាចាំបាច់ត្រូវតែរក្សាបេតិភណ្ឌទុកលើ ទីតាំងដដែល ហើយត្រូវចេញបទបញ្ជា ឬលិខិតបទដ្ឋានគតិយុត្តដើម្បីកម្រិតសិទ្ធិ ប្រើប្រាស់ដីនោះត្រឹមកំរិតជាក់លាក់ ដលមិននាំឱ្យប៉ះពាល់ខូចខាតបេតិកភ័ណ្ឌ នោះ ឬប្រកាសដីឯកជននោះ ជាកម្មវត្ថុនៃការដកហូតតាមផ្លូវច្បាប់ ដើម្បី ប្រយោជន៍ សាធារណៈដោយមានផ្តល់សំណងសមរម្យ និងយុត្តិធម៌ជាមុន ។ ដីដែលបានដកហូតនោះត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ (និងត្រូវមានការចូលរួមរបស់អាជ្ញាធរអប្សរា ក្នុងករណីតំបន់សៀមរាបអង្គរ) ត្រូវសិក្សានិងកំណត់ព្រំប្រទល់បរិវេណទីតាំងបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រដែលត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |

| | | | |
|---|---|---|---|
| | | - ពួមានការកំណត់តំបន់ដែលប្រជាពលរដ្ឋកាន់កាប់មុនឆ្នាំ១៩៥២ ឬ មុនការកាយើញដោយរដ្ឋនូវបេតិកភ័ណ្ឌនោះ និងបន្តកាន់កាប់ដោយស្របច្បាប់រហូតមក ទោះតាមរយៈការផ្ទេរក៏ដោយ ព្រោះពួកគេគួរទទួលបានកម្មសិទ្ធិ ឬសិទ្ធិប្រើប្រាស់លើដីនោះ ។ | |
| អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ ព្រះរាជវង្សានុវង្ស | - ច្បាប់ភូមិបាលឆ្នាំ ២០០១ មាត្រា ១៩ រាប់អចនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្សចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ | - ដីព្រះរាជវាំង ឬព្រះរាជដំណាក់ទាំងឡាយដែលឋិតនៅក្រោមការថែរក្សាការពារដោយក្រសួងព្រះបរមរាជវាំង គឺជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ដីដែលបានទិញ ឬកាន់កាប់ជាភោគៈ ឬទទួលបានជាកម្មសិទ្ធិតាមរយៈលទ្ធកម្មស្របច្បាប់ផ្សេងៗ ដោយសមាជិកនៃព្រះរាជវង្សានុវង្ស គឺជាដីឯកជនរបស់ព្រះរាជវង្សានុវង្ស ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ថាដីណាខ្លះជាព្រះរាជទ្រព្យ ដែលត្រូវចាត់ថ្នាក់ថា ជាដីសាធារណៈរបស់រដ្ឋ ។<br>- ការសិក្សា កំណត់ខាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |
| ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ | - មាត្រា ៤ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ចែងថា " .... ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ " ។<br>-ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤ មាត្រា ១២ ចែងថា " រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈ ដូចតទៅ :<br>- ទីបម្រុងទុកទឹក និងទំនប់ទឹក<br>- ទីបម្រុងជីករ៉ែនិងតំបន់ព្រៃឈើ<br>- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ<br>- សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍<br>- ដីបម្រុងទុកសម្រាប់ផ្លូវ បម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន<br>- ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរច្រាំង...... ។ | - ប្រឡាយ ឬអូរបង្ហូរទឹកស្អុយ នៅតាមដងផ្លូវដែលមិនទាន់បានរៀបចំ ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ ។<br><br>- ដីស្ថានីយរ៉ារីអគ្គីសនី ដីស្ថានីយចែកចាយភ្លើងរបស់រដ្ឋ ដីស្ថានីយចែកចាយទឹកស្អាតរបស់រដ្ឋ និងដីអាងស្តុកទឹករបស់រដ្ឋ ត្រូវចាត់ទុកជាដីសាធារណៈរបស់រដ្ឋ ។ | - យន្តការដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ ត្រូវសិក្សា និងកំណត់ដីដែលត្រូវចាត់ចូលក្នុងជំពូកដីសាធារណៈរបស់រដ្ឋនេះ ។<br><br>- ការសិក្សា កំណត់ាងលើនេះ ក៏ត្រូវផ្អែកលើផែនការប្រើប្រាស់ដី ប្រសិនបើមាន ។ |



nat

## III – ការគ្រប់គ្រង ថែរក្សា និងការពារដីរដ្ឋ :

ដើម្បីអាចគ្រប់គ្រង ថែរក្សា និងការពារដីរដ្ឋ ឱ្យមានប្រសិទ្ធភាព រាល់ដីរដ្ឋទាំងអស់ក្រោយពីបានកំណត់ ទីតាំង ព្រំប្រទល់ច្បាស់លាស់ ចុះបញ្ជី និងធ្វើចំណាត់ថ្នាក់រួចមក អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវរៀបចំបោះបង្គោលរបង សម្រាប់ចំណាំ ឱ្យសាធារណជនដឹង និងការពារដីនោះ។ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវទទួលខុសត្រូវ ជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។

ប្រការ ៣ : សេចក្តីសម្រេចនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត-ក្រុង
- ឯកសារ -កាលប្បវត្តិ